# បន្ទាប់ពីអគ្គិភ័យ៖ ការប្រើប្រាស់ សម្ភារបរិក្ខារការពារខ្លួនអ្នក

## ព័ត៌មានសហគមន៍

សម្ភារបរិក្ខារការពារខ្លួន
គឺសម្រាប់អ្នកដែលវិលត្រឡប់មកកន្លែងអចលទ្រព្យដែលរងផលប៉ះពាល់ដោយភ្លើងឆេះ។ សម្ភារបរិក្ខារការពារខ្លួនអាចរកបានពីសាលាសង្កាត់ក្នុងតំបន់របស់អ្នក ឬមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ រួមបន្ថែមជាមួយម៉ាស អៀមដែលអាចបោះចោលក្រោយពេលប្រើរួច និងស្រោមដៃធន់មាំ។

**គួរប្រើសម្ភារបរិក្ខារទាំងនេះ សម្រាប់តែការការពារផ្ទាល់ខ្លួនក្នុងអំឡុងពេលចុះពិនិត្យអចលនទ្រព្យប៉ុណ្ណោះ។**

**សម្ភារបរិក្ខារទាំងនេះ <u>មិនមែន</u>សម្រាប់យកចេញ ឬសម្អាតអាបែស្តូទេ។**

ព្រឹត្តបត្រព័ត៌មាន *បន្ទាប់ពីអគ្គិភ័យ៖ ការត្រឡប់មកកាន់គេហដ្ឋានវិញដោយសុវត្ថិភាព* មានដាក់នៅក្នុងសម្ភារបរិក្ខារនេះដែលរៀបរាប់យ៉ាងលម្អិតអំពីកត្តាពិចារណាពីសុខភាព និងសុវត្ថិភាពដែលអ្នកគួរដឹងមុនពេលវិលចូលគេហដ្ឋានរបស់អ្នកវិញ។

## សម្ភារបរិក្ខារការពារនីមួយៗមាន៖

- អៀមដែលអាចបោះចោលក្រោយពេលប្រើរួច
- ម៉ាសការពារមុខ P2 ដែលអាចបោះចោលក្រោយពេលប្រើរួច
- ស្រោមដៃធន់មាំ
- ថង់សំរាមដើម្បីទុកដាក់សម្ភារបរិក្ខារការពារដែលបានប្រើរួច។

ព្រឹត្តបត្រព័ត៌មាន៖

- *បន្ទាប់ពីអគ្គិភ័យ៖ ការត្រឡប់មកកាន់គេហដ្ឋានវិញដោយសុវត្ថិភាព*
- *បន្ទាប់ពីអគ្គិភ័យ៖ ការប្រើប្រាស់សម្ភារបរិក្ខារការពារខ្លួនអ្នក។*





## តើខ្ញុំនឹងត្រូវការសម្ភារប៉ុន្មាន ?

ដោយសារសម្ភារបរិក្ខារការពារអាចបោះចោលក្រោយពេលប្រើរួច ដូច្នោះមិនគួរយកវាមកប្រើម្តងទៀតទេ មនុស្សម្នាក់ៗអាចត្រូវការសម្ភារបរិក្ខារជាច្រើនអាស្រ័យលើពេលវេលាដែលត្រូវចំណាយនៅកន្លែងអចលនទ្រព្យ។

**គួរដោះចេញ និងបោះចោលម៉ាស អៀម និងស្រោមដៃ៖**

- **នៅពេលណាអ្នកឈប់សម្រាកពីការងារ**
- **នៅពេលណាអ្នកចាកចេញពីអចលនទ្រព្យរបស់អ្នក**
- **មុនពេលចូលរថយន្ត។**

**អ្នកគួរពាក់ស្បែកជើងធន់មាំ ដែលអាចសម្អាតយ៉ាងងាយស្រួល ឬលាងសម្អាតនៅពេលចាកចេញពីអចលនទ្រព្យរបស់អ្នក។**

## វិធីប្រើប្រាស់សម្ភារបរិក្ខារការពារ៖

- អនុវត្តតាមការណែនាំនៅទំព័រម្ខាងទៀត សម្រាប់ការណែនាំអំពីការពាក់ម៉ាសឲ្យបានត្រឹមត្រូវ -ត្រូវថា ពុកដឹត្រូចង្ការ និងពុកមាត់ធ្វើឲ្យបុរសពាក់ម៉ាសមិនបានជិតល្អ ។

គួរពាក់អៀមពីលើសម្លៀកបំពាក់របស់អ្នក។

## ដើម្បីដោះចេញ និងទុកដាក់សម្ភារបរិក្ខារការពារ ៖

- គួរដោះអៀមដែលអាចបោះចោលក្រោយពេលប្រើរួច ត្រឡប់ខាងក្នុងចេញមកក្រៅ រួចហើយដាក់នៅក្នុងថង់
- គួរដោះចេញស្រោមដៃចេញ ហើយដាក់នៅក្នុងថង់
- ដុសលាងស្បែកជើងឲ្យបានស្អាតបាត ប្រសិនបើមិនបោះចោលវាទេ
- ដោះម៉ាសការពារមុខចុងក្រោយ រួចដាក់វានៅក្នុងថង់
- ចងថង់ឲ្យបានតឹងជាមួយចំណងខ្សែ
- បោះចោលថង់នេះនៅកន្លែងប្រមូលសំរាមណាមួយ។

## សម្រាប់ព័ត៌មានបន្ថែម

សូមទាក់ទងសាលាសង្កាត់ក្នុងតំបន់របស់អ្នក ឬមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ដើម្បីទទួលបានសម្ភារបរិក្ខារការពារបន្ថែម ឬប្រសិនបើអ្នកមានសំណួរអំពីការប្រើសម្ភារបរិក្ខារ។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលវិចតូរីយ៉ា 1 Treasury Place, Melbourne។
© រដ្ឋវិចតូរីយ៉ា Department of Health and Human Services ខែកុម្ភៈ ឆ្នាំ២០១៦។

VICTORIA State Government | Health and Human Services

# វិធីពាក់ម៉ាស P2 ឬ N95 និងពិនិត្យមើលឲ្យបានត្រឹមត្រូវ




ញែកគែមម៉ាសចេញពីគ្នា ដើម្បីឲ្យវាបើកបានពេញ




ពត់ខ្សែលួសច្រមុះម៉ាសឲ្យមានរាងជាខ្សែកោងបន្តិច។
ខ្សែលួសច្រមុះម៉ាសគឺជាផ្នែកខាង




កាន់ម៉ាសបញ្ច្រាសដើម្បីឲ្យឃើញខ្សែចងពីរ




ញែកខ្សែពីរចេញពីគ្នាដោយប្រើម្រាមដៃចង្អុល និងមេដៃអ្នក




ខណៈកំពុងកាន់ខ្សែចងពាក់ម៉ាស ក្តោបម៉ាសជារាងពែងនៅក្រោមចង្ការអ្នក




ទាញខ្សែចងឡើងលើ ហើយដាក់ពីលើក្បាលអ្នក




ដាក់ខ្សែចងផ្នែកខាងក្រោមនៅគល់កញ្ចឹងកអ្នក




ដាក់ខ្សែចងផ្នែកខាងលើកំពូលក្បាលអ្នក
ដើម្បីឲ្យខ្សែនោះនៅចំពីលើត្រចៀកអ្នក




សង្កត់ខ្សែលួសច្រមុះម៉ាសថ្នមៗកាត់តាមខ្នង់ច្រមុះអ្នក
រហូតទាល់តែពាក់វាបានត្រឹមត្រូវ




បន្តកែសម្រួលម៉ាស
និងគែមម៉ាសរហូតទាល់តែអ្នកមានអារម្មណ៍ថាពាក់បានស្រួល និងត្រឹមត្រូវ

## ការពិនិត្យឲ្យសមត្រឹមត្រូវ

ស្រូបដង្ហើមចូលមួយៗ
នៅពេលអ្នកដកដង្ហើមនៅក្នុងម៉ាស
វាគួរតែស្រូបចូល




**ការពិនិត្យឲ្យសមត្រឹមត្រូវ
ត្រូវអនុវត្តរាល់ពេលពាក់
ម៉ាស P2 ឬ N95**




ដកដង្ហើមចេញមួយៗ។
ម៉ាសគួរតែមានខ្យល់គ្រប់គ្រាន់។
វាជាការសំខាន់នៅក្នុងដំណាក់កាលនេះ
មិនមានការលេចធ្លាយខ្យល់នៅជុំវិញគែម

អនុវត្តតាមការណែនាំទាំងនេះ រាល់ពេលពាក់ម៉ាស។ ម៉ាសនឹងមិនផ្តល់នូវកម្រិតនៃការការពារដែលចង់បាននោះទេក្នុងករណីពាក់មិនត្រឹមត្រូវ ដូច្នេះហើយវាជាការសំខាន់ដែលអ្នកត្រូវពាក់ឲ្យបានសម និងត្រឹមត្រូវ ដូចដែលបានរៀបរាប់លម្អិតខាងលើនេះ។ បុរសដែលបានកោរពុកមាត់ នឹងអាចពាក់បិទមុខបានជិតល្អ។ ម៉ាសម៉ាក P2 ឬ N95 អាចខុសគ្នាបន្តិច ដូច្នេះត្រូវអនុវត្តតាមការណែនាំ និងការព្រមានរបស់អ្នកផលិត។